ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៧ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០០៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៧

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទមេត្តាជ្រាបថា : ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ត្រូវចាប់អនុវត្តពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ ។

<u>ពន្ធនេះត្រូវបានលើកលែងមិនប្រមូលចំពោះ</u> :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៧ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញនូវលិខិតប្រកាសចំនួន០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំងត្រូវបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបញ្ជាក់ការបង់ពន្ធសំរាប់ឆ្នាំ២០០៦ សំរាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ រួចហើយ ។ ក្នុងករណីបាត់បង្កាន់ដៃបញ្ជាក់ការបង់ពន្ធសំរាប់ឆ្នាំ២០០៦ ម្ចាស់មធ្យោបាយនិងយានជំនិះត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ ចេញដោយរដ្ឋបាលសារពើពន្ធ នៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ ឬ ប្រកាសបង់ពន្ធនៅទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ ដើម្បីមានការងាយស្រួលបញ្ជាក់ផ្ទៀងផ្ទាត់ជាមួយគល់ប័ណ្ណបង្កាន់ដៃបង់ពន្ធឆ្នាំ២០០៦ ដែលផ្នែកពន្ធរក្សាទុក ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលពុំមានបង្កាន់ដៃបញ្ជាក់ពីការបានបង់ពន្ធឆ្នាំ២០០៦ ទេនោះ ត្រូវបង់ពន្ធសំរាប់ឆ្នាំ២០០៦ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៧។

ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនិមួយៗ ត្រូវបានទទួលប័ណ្ណបង់ពន្ធមួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនិមួយៗ និង បង្កាន់ដៃបង់ពន្ធមួយសន្លឹកទៀត ។ ម្ចាស់មធ្យោបាយ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវរក្សាទុកបង្កាន់ដៃបង់ពន្ធ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។

ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៧ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧ តទៅ ។

ការត្រួតពិនិត្យនេះ និង ត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយ ក្នុងភូមិ ឃុំ សង្កាត់ ... និង ទីចំណតនានា ។

ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និង ត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធខេត្ត-ក្រុង នៅរៀងរាល់ថ្ងៃធ្វើការ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ ២០០៧ នេះ ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាប្រញាប់ប្រញាល់រួសរាន់អញ្ជើញទៅបង់ពន្ធនេះអោយបានមុនថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ កុំបីខាន ។/

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់